# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
***********

# កិច្ចសន្យា
## ស្ដីពី
# ការវិនិយោគទុន លើដំណាំកសិកម្ម និង កែច្នៃ
## រវាង
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## និង
# ក្រុមហ៊ុន សាជីវកម្ម ស៊ី.ជេ ខាំបូឌា ចំកាត់
******

<u>កិច្ចសន្យានេះធ្វើឡើងរវាង:</u>

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានអាស័យដ្ឋានលេខ: ២០០ មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣២០ មានគណនីលេខ : ០១០៦៣២២០ នៅធនាគារពាណិជ្ជកម្មក្រៅប្រទេស ហៅថា ភាគី "ក" ។

*<u>ជាមួយនិង</u>*

ក្រុមហ៊ុនសាជីវកម្ម ស៊ី.ជេ ខាំបូឌា ចំកាត់(CJ Cambodia Co., Ltd) មានអាស័យដ្ឋាន ផ្ទះលេខ ១៤ ផ្លូវលេខ ២០៨ សង្កាត់ បឹងរាំ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទលេខ (៨៥៥-២៣ )២១៨ ៧២៩ និង ទូរសារលេខ ( ៨៥៥ - ២៣ ) ២១៨ ៧៣០ ដែលតំណាងដោយ លោក អ៊ី . ជេ . ឆយ (Mr.E.J. CHOI) ជនជាតិ កូរ៉េ លិខិតឆ្លងដែនលេខ NW 0467617 មានគណនី លេខ : ៥១០-៨០១៨៣៧-១ នៅធនាគារStandard & Chartered ដែល មានអាស័យដ្ឋាន លេខ ៨៩ មហាវិថី ព្រះនរោត្តម សង្កាត់ បឹងរាំង ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ហៅថាភាគី "ខ" ។

-យោងតាមលិខិតលេខ ១២២២ / ១៣៥ កសក.ជ.ផក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០០១ របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-យោងតាមខ្លឹមសារលិខិតជូនដំណឹងលេខ ៣២៣ ស.ជ.ណ ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០១ របស់ ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពី ករណីស៊ីវិនិយោគលើវិស័យ កសិកម្មដំណាំដំឡូងមី និង ផលិតកម្មកសិកម្មផ្សេង ៗ ទៀតនៅលើដីសម្បទាននេះ ។

-លិខិតសិទ្ធប្រទានលេខ ២១សប្រទ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០១ របស់ រាជរដ្ឋាភិបាលកម្ពុជា.

-ដោយផ្អែកលើច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ មានដូចខាងក្រោមនេះ :

## ប្រការ ១ : កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបប្រមាណ ចំនួន ៥.០០០ ហិកតា នូវដីដែលមានទីតាំងស្ថិតនៅក្នុង ស្រុកភ្នំស្រួច ខេត្ត កំពង់ស្ពឺ ត្រង់ចំណុច

| | | |
|---|---|---|
| A = 14 – 31 | B = 14–34 | C = 14.5–34 |
| C' = 14,5 – 35 | D = 18–35 | E = 18–37,5 |
| F = 19–38 | G = 21–38 | H = 23–40 |
| I = 24–40 | J = 24–31 | |

ដើម្បីដំណើរការវិនិយោគកសិកម្មដំណាំដំឡូងមីនិងផលិតកម្មកសិកម្មផ្សេងៗទៀតដូចមានផែនទីកំណត់ទីតាំងដែលភ្ជាប់មកជាមួយកិច្ចសន្យានេះ ។

ផ្ទៃដីសរុបចំនួន ៥.០០០ ហិកតា ខាងលើនេះមាន :

១.១ ដីដែលភាគី "ខ" អាចធ្វើអាជីវកម្មដោយផ្ទាល់

១.២ ដីជាកម្មសិទ្ធិរបស់ពលរដ្ឋកាន់កាប់ដែលក្រុមហ៊ុនអាចសហការធ្វើអាជីវកម្មជាមួយពលរដ្ឋដោយ មានការយល់ព្រមទាំងសងខាង ។

១.៣ ដីជាដីភ្នំ-ដីអាងទឹក និង ផ្សេងៗ ត្រូវរក្សាទុកអោយស្ថិតនៅជាលក្ខណៈធម្មជាតិ ។

១.៤ ចំនួនផ្ទៃដីដែលមានចែងក្នុងចំនុច ១.១ , ១.២ , ១.៣ ភាគី "ក" និង ភាគី "ខ" ត្រូវសហការ និងស្ថាប័នមានសមត្ថកិច្ច សិក្សាស្រាវជ្រាវអង្កេត និងកំណត់ច្បាស់លាស់គ្រប់ក្នុងរយៈពេល ៣ ខែ ក្រោយពីកិច្ចសន្យាត្រូវបានចុះហត្ថលេខា ហើយត្រូវកាត់ចេញផ្ទៃដីពាក់ព័ន្ធទាំងអស់នេះចេញពីតំបន់វិនិយោគរបស់ខ្លួន ។ រាល់ការចំណាយលើការអង្កេតនេះជាបន្ទុករបស់ ភាគី "ខ" ។

## ប្រការ ២ : អំពីរយៈពេល

២.១ កិច្ចសន្យានេះមានរយៈពេល ៧០ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី..24.....ខែ..04...ឆ្នាំ ២០០១ ដល់ថ្ងៃទី..24......ខែ...04....ឆ្នាំ ២០៧១ ។ កម្មសិទ្ធិនេះនឹងត្រូវប្រគល់ជូនរដ្ឋវិញនៅពេលណាដែលកិច្ចសន្យានេះចូលជាធរមាន ។ សេចក្តីជូនដំណឹងបញ្ចប់កិច្ចសន្យាត្រូវផ្តល់ជាមុនចំនួន ៩០ថ្ងៃ ឬ នៅក្នុងឆ្នាំចុងក្រោយនៃកិច្ចសន្យាក្នុងករណីដែលកិច្ចសន្យានេះបន្តលើសពី ៧០ឆ្នាំ ។

២.២ ភាគី "ខ" មានសិទ្ធិពេញលេញដើម្បីសុំបន្តកិច្ចសន្យាជុំថ្មីបន្ទាប់ពីរយៈពេល ៧០ឆ្នាំ។ ចំណែកសិទ្ធិផលដែលបានមកពីដីនេះ ត្រូវតែជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ស៊ីជេ ខេមបូឌា ចាំកាត់ (CJ Cambodia Co., Ltd.) ។ ប្រសិនបើភាគី "ខ" សុំបន្តការជួល កាលបរិច្ឆេទទាំងឡាយនៅក្នុងកិច្ចសន្យានេះត្រូវ កំណត់ជាថ្មី ដោយ

ស្វ័យប្រវត្តិសំរាប់ការបន្តជួល ហើយភាគី "ខ" មានសិទ្ធិចុះកិច្ចសន្យាឡើងវិញជាមួយ និង ភាគី "ក" ។ លិខិតជូនដំណឹងត្រូវប្រគល់ជូនភាគី "ក" មុនការ បន្តកិច្ចសន្យាចំនួន ៩០ថ្ងៃ ។ នៅពេលបន្តកិច្ចសន្យាថ្មីថ្លៃជួលនឹងត្រូវកំណត់តាមគោលការណ៍ និង សេចក្តីសំរេច របស់ រាជរដ្ឋាភិបាល ។ ប្រសិនបើភាគីមិនអាចឯកភាពគ្នាទៅលើតំលៃជួល សំរាប់រយៈពេល នោះ ទេភាគីទាំងពីរនឹងត្រូវពិគ្រោះ

ជាមួយ ក្រុមហ៊ុនឯទៀតដែលប្រកបរបរប្រហាក់ប្រហែលគ្នានៅក្នុង ព្រះរាជាណាចក្រកម្ពុជាដើម្បីធ្វើការសំរេចលើតំលៃ ទិផ្សារសមស្របមួយសំរាប់ការជួល ។

## ប្រការ៣ : គោលបំណង និង កម្មវិធី

៣.១ ភាគី "ខ" មានបំណងកសាង និង ដំណើរការ កសិកម្មដំណាំដំឡូងមី និង ផលិតកម្មកសិកម្មផ្សេង ១ទៀត នៅលើដីនេះដោយពុំមានការហាមឃាត់ក្នុងការធ្វើផលិតកម្ម-អាជីវកម្មលើដីនេះឡើយ ។ ផលចំណេញដែលបានមកពីដីនេះ គឺជាកម្មសិទ្ធិស្របច្បាប់របស់ក្រុមហ៊ុន ស៊ី.ជេ ខាំបូឌា ចំកាត់ (CJ Cambodia Co., Ltd) ។

៣.១.១ ផលិតកម្មចំបង : កសិកម្មដំណាំដំឡូងមី

៣.១.២ ផលិតកម្មបន្ទាប់បន្សំ : ផលិតកម្មកសិកម្មផ្សេង ១ ទៀត

៣.១.២ ការសាងសង់ : រោងចក្រ កែច្នៃផ្សេង ១

៣.២ កម្មវិធីប្រើប្រាស់ទីតាំងដីសម្បទាន : ភាគី "ខ" ត្រូវប្រើផ្ទៃដីដែលបានរៀបរាប់ក្នុងប្រការ ១ នៃ កិច្ចសន្យានេះ អោយចប់សព្វគ្រប់ក្នុងរយៈពេល ៥ ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះ ទៅ ។

## ប្រការ ៤ : វិធីប្រាក់កក់ និងថ្លៃឈ្នួល

៤.១ ប្រាក់កក់: ភាគី "ខ" ត្រូវបង់ប្រាក់កក់ចំនួនស្មើ $1 (មួយដុល្លាអាមេរិក) ក្នុងមួយហិកតាសំរាប់បានាការអនុវត្តន៍កិច្ចសន្យានេះ ។ ប្រាក់កក់នេះត្រូវបង់តាមចំនួនផ្ទៃដីនៃប្រការ ១ យ៉ាងយឺតបំផុតរយៈពេល [illegible] ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យា ។ ប្រាក់កក់នេះត្រូវបង្វិលសងវិញនៅពេល ដែលភាគី "ខ" អនុវត្តន៍ការដាំដុះចប់តាមគំរោងក្នុងប្រការ ៣ ។

៤.២ ភាគី "ខ" ត្រូវបង់ ថ្លៃឈ្នួលដីប្រចាំឆ្នាំ តាមអត្រាថ្លៃឈ្នួលដីសម្បទាននឹងតាមរបបរដ្ឋកំណត់ ។

៤.៣ ប្រាក់ថ្លៃឈ្នួលដី និងប្រាក់កក់ធានាការអនុវត្តន៍ត្រូវបង់ចូលថវិការដ្ឋ នៅរតនាគាជាតិ-គណនី របស់ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៤.៤ ភាគី "ខ" ត្រូវមានភាតព្វកិច្ចបង់ពន្ធផ្សេង ៗ ទៀតជូនរដ្ឋ តាមច្បាប់ជាធរមាន ។

## ប្រការ ៥ : ការប្រគល់សិទ្ធិ និង សហការនៃកិច្ចសន្យា

៥.១ ភាគី "ខ" មានសិទ្ធិផ្ទេរ និង សហការលើដីសម្បទាន និង ទ្រព្យសម្បត្តិជាផ្នែកទៅអោយអ្នកទទួលបន្ត ឬ អ្នក ដែលទទួលការចាត់តាំងដោយធ្វើលិខិតជូនដំណឹងមុនចំនួន ៦០ថ្ងៃ ទៅភាគី "ក" ។ ភាគី "ខ" មាន សិទ្ធិ សហការលើដីបន្តអោយទៅភាគី ទី ៣ ណាមួយបានដោយភាគី ទី ៣ នោះត្រូវតែគោរពតាមកិច្ចសន្យាដែល ធ្វើឡើង រវាង ភាគី "ក" និង ភាគី "ខ" ។ ភាគី "ក" មិនទទួលចំណេញអ្វីពីការសហការបន្តនេះឡើយ ។ ភាគី "ខ" នៅតែជាអ្នក ទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់ និង កិច្ចសន្យានេះ ជាមួយភាគី "ក" ដដែល ។

៥.២ ភាគី "ខ" ពុំអាចលក់កិច្ចសន្យានេះ ទោះជាក្នុងរូបភាពណាក់ដោយអោយទៅតតិយជនផ្សេង ទៀតបាន ឡើយ ។ ក៏ប៉ុន្តែភាគី "ខ" ក្រោមសិទ្ធិទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់ និង កិច្ចសន្យានេះ អាច សហការជាមួយក្រុមហ៊ុនដៃគូរបស់ខ្លួនបានដើម្បីអភិវឌ្ឍន៍ ផលិតកម្ម - អាជីវកម្ម ដែលស្ថិតនៅក្នុង ក្របខ័ណ្ឌ ដែលមានចែងក្នុងកិច្ចសន្យានេះ ។ ក្នុងករណីនេះភាគី "ខ" នៅតែជាបុគ្គលទទួលខុសត្រូវក្នុង កិច្ចសន្យាដដែល ។

## ប្រការ ៦ : សិទ្ធិ និង ភាតព្វកិច្ចរបស់ភាគី "ក"

*<u>ភាគី "ក" មានសិទ្ធិ និង ភាតព្វកិច្ចដូចខាងក្រោម:</u>*

៦.១ ជួយរិះរកវិធានការចាំបាច់ទៅស្ថាប័នដែលពាក់ព័ន្ធដើម្បីដោះស្រាយឧប្បត្តិហេតុណាមួយដែលមានអ្នកប្រព្រឹត្ត បទល្មើសរំលោភលើសិទ្ធិរបស់ភាគី "ខ" ក្នុងក្របខ័ណ្ឌកិច្ចសន្យានេះក្នុងការអភិវឌ្ឍន៍ និង ការប្រើប្រាស់ ទីតាំង ឬ រឹបអូសយកផ្នែកណាមួយនៃទីតាំង ។

៦.២ តាមដានត្រួតពិនិត្យលើ :

៦.២.១ ការអនុវត្តន៍កិច្ចសន្យា

៦.២.២ ផលប៉ះពាល់លើបរិស្ថាន

៦.២.៣ ការងារបច្ចេកទេស និង កម្មវិធីផលិតកម្ម-អាជីវកម្ម

៦.៣ ភាគី "ក" ធានា និងសហការផ្តល់លិខិតអនុញ្ញាតិទាំងឡាយពីរាជរដ្ឋាភិបាលកម្ពុជា និង ស្ថាប័នរដ្ឋាភិបាល ដែលជាប់ពាក់ព័ន្ធដើម្បីអោយភាគី "ខ" អាចចុះកិច្ចសន្យាបានដោយស្របច្បាប់ដើម្បីប្រើប្រាស់ដីនេះតាម

គោលបំណងដែលបានកំណត់ក្នុង ប្រការ៣.១ និង ៣.២ សំរាប់គ្រប់ពេលទាំងអស់ ក្នុងពេលជាប់កិច្ចសន្យា ។

៦.៤ ក្រៅពីភាគី "ក" គ្មានភាគី ទី៣ និងគ្មានផ្នែកណាមួយ នៃ រាជរដ្ឋាភិបាលកម្ពុជា និងគ្មានមន្ត្រីណាមួយមានសិទ្ធិទាមទារយកដីនេះបានឡើយនៅក្នុងពេលជាប់កិច្ចសន្យា ។

៦.៥ ភាគី "ក" ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅភាគី "ខ" ក្នុងរយៈពេល ៣ សប្តាហ៍ ជាមុនដើម្បីចូលពិនិត្យទ្រព្យសម្បត្តិ និង កែលំអអ្វីមួយឡើងវិញនៅលើដីសម្បទាន ។

៦.៦ ភាគី "ក" ធានានិងសន្យាថា ខ្លួនបានធ្វើកិច្ចសន្យាជួលដីនេះដោយស្របច្បាប់ជាមួយភាគី "ខ" មួយគត់សំរាប់អាណត្តិកិច្ចសន្យានេះនិងមិនមានពាក់ព័ន្ធលើបន្ទុកចលនវត្ថុ អ្នកដាក់បញ្ចាំសិទ្ធិឃាត់ទុកឡើយ ។

## ប្រការ ៧ : សិទ្ធិ និង ភារកិច្ចរបស់ភាគី "ខ"

ភាគី "ខ" មានសិទ្ធិ និង ភារកិច្ចដូចខាងក្រោម :

៧.១ យល់ព្រមបង់ប្រាក់កក់ និង ថ្លៃឈ្នួលត្រឹមត្រូវតាមប្រការ ៤ នៃកិច្ចសន្យានេះរហូតដល់ពេលចប់អាណត្តិកិច្ចសន្យា ។

៧.២ ភាគី "ខ" យល់ព្រមទទួលបន្ទុកចំណាយលើការអង្កេតសិក្សាដូចមានចែងក្នុងប្រការ ១.៤ ។

៧.៣ មានសិទ្ធិជ្រើសរើសពលករក្នុងស្រុក ឬ ជួលអ្នកឯកទេសបរទេសដើម្បីជួយណែនាំឬបង្ហាត់ បង្ហាញអំពីការងារបច្ចេកទេសអាជីវកម្ម-ផលិតកម្មតាមសេចក្តីត្រូវការចាំបាច់របស់ខ្លួន ក្នុងករណីគ្មានអ្នកឯកទេសនៅក្នុងប្រទេសដោយគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

៧.៤ យកចិត្តទុកដាក់ចំពោះជីវភាពរស់នៅក៏ដូចជាសុខភាព និង ការអប់រំដល់បុគ្គលិក កម្មករ និង ខិតខំកសាងកន្លែងស្នាក់អាស្រ័យ និង មណ្ឌលសុខភាព ។ល។

៧.៥ អនុវត្តការងារអាជីវកម្មតាមគំរោងផែនការដូចជា: ការកាប់ឆ្ការព្រៃ ការធ្វើផ្លូវ ការដាំដុះនិងថែទាំ ។ល។ ដោយគោរពលក្ខខ័ណ្ឌនិរន្តរភាព របស់ទីតាំងនិងផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមកពីការធ្វើអាជីវកម្ម-ផលិតកម្ម ។

៧.៦ រៀបចំធ្វើផលិតកម្ម-អាជីវកម្មតាមផែនការដូចមានចែងក្នុងរបាយការណ៍បច្ចេកទេសសេដ្ឋកិច្ចរបស់ខ្លួន និង ដូចក្នុងប្រការ ៣ នៃកិច្ចសន្យានេះនៅលើផ្ទៃដីដែលរដ្ឋប្រគល់ជូន ។

៧.៧ មានសិទ្ធិលក់ដូរប្រមូលទិញបែងចែកចរាចរផលិតផលគ្រប់ប្រភេទទាំងនៅក្នុង និង ក្រៅប្រទេសតាមគោលការណ៍រដ្ឋជាធរមាន ។

៧.៨ ចំពោះការនាំចូលនូវសំភារៈគ្រឿងចក្រ គ្រឿងបន្លាស់ វត្ថុធាតុដើមដែលបំរើអោយការធ្វើផលិតកម្ម-អាជីវកម្ម និង ការបង់ពន្ធនានាផ្សេងៗ គឺអាស្រ័យដោយច្បាប់ របស់ព្រះរាជាណាចក្រកម្ពុជាកំណត់ ។

៧.៩ ត្រូវអនុវត្តតាមការណែនាំរបស់ភាគី "ក" និង ស្ថាប័នពាក់ព័ន្ធ តាមដាន ត្រួតពិនិត្យវាយតំលៃ អំពីផលប៉ះពាល់បរិស្ថាន ។ ត្រូវអនុវត្តតាមការណែនាំរបស់ភាគី "ក" និង ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការពារបរិស្ថាន ។

៧.១០ ភាគី "ខ" មានកាតព្វកិច្ចទិញយកផលិតផលជ័រឡាំងមីគ្រប់គ្រាន់ ពីកងយោធពលខេមរៈភូមិន្ទកម្ពុជា អាស្រ័យ ទៅតាមគុណភាពជ័រឡាំង និង តំលៃទីផ្សារ ។

## ប្រការ ៨ : ការអនុញ្ញាតិអោយសាងសង់

៨.១ តាមរយៈនេះភាគី "ខ" ត្រូវបានអនុញ្ញាតិអោយអនុវត្តរាល់កិច្ចការសំណង់លើទីតាំងដែលស្របតាមច្បាប់ជាធរមាន នៃ ព្រះរាជាណាចក្រកម្ពុជា និងសមស្រប នឹង ទិសដៅការងារក្នុងប្រការ ៣ នៃកិច្ចសន្យានេះ ។

៨.២ រាល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេង ៗ ដូចជា ទំនប់ ប្រឡាយ ដែលអាចអោយមានផលប៉ះពាល់ដល់តំបន់ ជុំវិញ ត្រូវមានការអនុញ្ញាតិពីភាគី "ក" ឬស្ថាប័នពាក់ព័ន្ធ ។

## ប្រការ ៩ : សិទ្ធិនៃការគ្រប់គ្រង

រាល់អចលនៈទ្រព្យ និង ហេដ្ឋារចនាសម្ព័ន្ធព្រមទាំងសមិទ្ធិផលទាំងអស់ដែលបង្កើតឡើងដោយ ភាគី "ខ" ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគី "ខ" រហូតផុតរយៈពេលនៃកិច្ចសន្យា ។

## ប្រការ ១០ : ការបញ្ចប់កិច្ចសន្យា

១០.១ ភាគី "ខ" មានសិទ្ធិដកហូតចេញពីគំរោងការងារទាំងមូល ឬផ្នែកណាមួយក្នុងលក្ខខ័ណ្ឌមិនអាចគ្រប់គ្រងបាន និង ត្រូវមានការឯកភាពពីភាគីទាំងសងខាង ។ រដ្ឋាភិបាលធានានូវការវិលត្រឡប់ប្រកបដោយសុវត្ថិភាពបុគ្គលិកបរទេសរបស់ក្រុមហ៊ុន និង ក្រុមគ្រួសាររបស់ពួកគេហើយការដកត្រឡប់ទៅវិញ ឬ ការលក់សំភារៈបរិក្ខា រោងចក្រនានា នាវាដាក់ម៉ាស៊ីន នាវាដឹកទំនិញ យានយន្តផ្សេង ៗ ទៀត និង ប្រដាប់ប្រដារ ព្រមទាំងមធ្យោបាយដឹកជញ្ជូនផ្សេង១ទៀត គ្រឿងដាក់ភ្ជាប់នៅមួយកន្លែងត្រូវធ្វើទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាន ។

១០.២ ក្នុងករណីដែលភាគី "ខ" ដកខ្លួនដោយខ្លួនឯងនោះ ភាគី "ខ" ត្រូវទទួលខុសត្រូវតាមមាត្រាទី ២៣ នៃ ច្បាប់វិនិយោគ ហើយប្រាក់កក់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

១០.៣ ប្រសិនបើភាគី "ខ" មិនអនុវត្តពេញលេញនូវលក្ខខ័ណ្ឌណាមួយនៃកិច្ចសន្យានេះ ឬសេចក្តីសំរេចនានានៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។ រដ្ឋាភិបាលមានសិទ្ធិបញ្ចប់កិច្ចសន្យានេះដោយគ្មានលក្ខ័ណ្ឌ និង មិនសងការខាតបង់ ។ ការបញ្ចប់បែបនេះនឹងនាំអោយមាន ការរឹបអូសប្រាក់កក់របស់ ភាគី "ខ" ជា សម្បត្តិរដ្ឋ "

១០.៤ ក្នុងករណីដែលភាគី "ខ" មិនបានគោរពតាមកិច្ចសន្យានេះ ដោយមិនបានចាប់ផ្តើមសកម្មភាពផលិតកម្ម នៅក្នុងតំបន់ដីសម្បទានក្នុងរយៈពេល ១ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះ រដ្ឋាភិបាលមានសិទ្ធិបញ្ចប់កិច្ចសន្យាដោយគ្មានលក្ខខ័ណ្ឌនិង គ្មានការសងនូវការខាតបង់ ។ ការបញ្ចប់បែបនេះ នឹងនាំអោយមានការរឹបអូសប្រាក់កក់របស់ ភាគី "ខ" ជាសម្បត្តិរដ្ឋ ។

## ប្រការ ១១ : វិវាទ និង ការដោះស្រាយ (អាជ្ញាកណ្តាល )

១១.១ ក្នុងករណីដែលមានវិវាទកើតក្នុងរយៈពេលនៃការអនុវត្តន៍កិច្ចសន្យានេះ ភាគីទាំងពីរ នឹងសំរបសំរួលដោះស្រាយដោយយោងទៅតាមសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីនីមួយៗដែលមានចែងក្នុងកិច្ចសន្យានេះ ។

១១.២ ក្នុងករណីដែលភាគីទាំងពីរមិនអាចសំរបសំរួល ឬ ដោះស្រាយវិវាទនេះបានក្នុងរយៈពេល ៦០ថ្ងៃ វិវាទ នេះត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជួយសំរួល និង ដោះស្រាយ ។

១១.៣ ក្នុងករណីដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានៅតែមិនអាចដោះស្រាយវិវាទនេះបានក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពីបានទទួលសំណើដូចមានចែងក្នុងចំនុចប្រការ ១១.២ ភាគីទាំងពីរត្រូវបញ្ជូនសំណុំឯកសារនៃវិវាទនេះទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការវិនិច្ឆ័យតាមច្បាប់ ជាធរមាន ។

១១.៤ ភាគីទាំងពីរឯកភាពគ្នាដោះស្រាយនូវភាពមិនចុះសំរុងគ្នាដោយលក្ខណៈជាមិត្តភាពនៅក្នុងប្រទេសកម្ពុជា ។ ក្នុងករណីដែលភាពមិនចុះសំរុងគ្នាមិនអាចដោះស្រាយបានភាគីទាំងពីរ ប្រគល់អោយ ទៅសាលាជំរះក្តីកណ្តាលផ្នែកពាណិជ្ជកម្ម រឺ សាលាកាត់ក្តី ដ៏ទៃទៀត ដែលមានសមត្ថកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រសិនបើពុំអាចដោះស្រាយបានក្នុងប្រទេស ភាគីទាំងពីរយល់ព្រមត្រូវប្រគល់ការដោះស្រាយទៅអោយអាជ្ញាកណ្តាលកាត់ក្តីនៅប្រទេសសិង្ហបូរីដោយយោងទៅតាមបទបញ្ញត្តិកាត់ក្តីដោយអាជ្ញាកណ្តាល អន្តរជាតិនៅប្រទេស សិង្ហបូរី ។ ភាសាដែលប្រើសំរាប់អាជ្ញាកណ្តាលគឺ ភាសាខ្មែរ និង អង់គ្លេស ។ ភាគីទាំងពីរ ត្រូវទទួលខុស ត្រូវរៀងៗខ្លួនលើការបកប្រែ ។

## ប្រការ ១២ : ការព្រមព្រៀងទាំងស្រុង

ឯកសារនេះមានការព្រមព្រៀងទាំងស្រុងដោយភាគីទាំងពីរ និងជំនួសអោយការទំនាក់ទំនង និមិត្តរូប និង ការព្រមព្រៀងទោះជាដោយពាក្យសំដី ឬ ដោយលាយល័ក្ខអក្សរដែលជាប់ទាក់ទិន នឹងបរិវេណដីនេះ ។ កិច្ចសន្យានេះ មិនអាចកែប្រែបានទេលុះត្រាតែមានលិខិតព្រមព្រៀងដែលចុះហត្ថលេខាដោយភាគីទាំងពីរ ។

## ប្រការ ១៣ : ផ្លាកយីហោ

សាជីវកម្មស៊ី.ជេ ខាំបូឌា ចំកាត់ អាចដាក់ផ្លាកសញ្ញាផ្សាយពាណិជ្ជកម្ម ឬផ្លាកផ្សេងៗដែលជាប់ពាក់ព័ន្ធ នឹងមុខរបររបស់ក្រុមហ៊ុន ។ ផ្លាកសញ្ញាទាំងអស់ដែលទាក់ទងនឹងមុខរបររបស់ក្រុមហ៊ុន ស៊ី.ជេ ខាំបូឌា ចំកាត់ ត្រូវតែស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១៤ : ពន្ធដា

ភាគី "ខ" យល់ព្រមទទួលខុសត្រូវបង់ពន្ធ ឬថ្លៃឈ្នួលផ្សេងៗ ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា រួមទាំង បញ្ចូល[illegible]ដែលអាចកំណត់ដោយច្បាប់ក្នុងពេលអនាគត ។

## ប្រការ ១៥ : ភាពមិនអាចយកជាការបានដោយអន្លើ

ប្រសិនបើមានពាក្យពេចន៍មួយចំនួនក្នុងកិច្ចសន្យានេះមិនអាចយកជាការបាន ឬ មិនអាចអនុវត្តបានទេនោះ ផ្នែកដែលនៅសល់ត្រូវតែយក ជាការបានតាមកំរិតដែលច្បាប់អនុញ្ញាតិ ។

## ប្រការ ១៦ : ច្បាប់អភិបាល

ការព្រមព្រៀងនៃកិច្ចសន្យានេះ ត្រូវគ្រប់គ្រងដោយច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១៧ : ការទុកជាមិនបានការទូទាត់ខ្លះ

ឯកសារនេះមានការព្រមព្រៀងទាំងស្រុងពីភាគីទាំងពីរ ហើយបដិសេធចោលនូវការប្រាស្រ័យទាក់ទង ការ តំណាង និង ការព្រមព្រៀងទាំងអស់ដែលមានពីមុន មិនថាដោយផ្ទាល់មាត់ ឬ ដោយសរសេរជាលាយលក្ខអក្សរ ដោយ គ្មានចុះហត្ថលេខា និង ទទួលស្គាល់ ដោយភាគីទាំងពីរ ។

## ប្រការ ១៨ : ករណីប្រធានសក្តិ

ក្នុងព្រឹត្តិការណ៍ដែលភាគីទាំងពីរមិនអាចបំពេញករណីកិច្ចរបស់ខ្លួនជាផ្នែក ឬ ទាំងស្រុងបានអនុលោមទៅតាម លក្ខខ័ណ្ឌផ្សេងៗ នៃកិច្ចសន្យានេះដោយសារតែករណីប្រធានសក្តិ ភាគី "ខ" ត្រូវប្រកាសប្រាប់ ភាគី "ក" ដោយ សរសេរជាលាយលក្ខអក្សរបញ្ជាក់ពីហេតុផលរបស់ខ្លួន ហើយកាតព្វកិច្ចរបស់ភាគី "ខ" នឹងត្រូវបញ្ឈប់ជាបណ្តោះ អាសន្ននៃរយៈពេលដែលជាប់ពាក់ព័ន្ធនោះ ។

ពាក្យ: " ករណីប្រធានសក្តិ " រួមមានភ្លើងឆេះ ទឹកជំនន់ ខ្យល់ព្យុះ សង្គ្រាម រញ្ជួយផែនដី ។ល។ ការរំដើបរំជួលនៃផ្នែកស៊ីវិល សកម្មភាពការបះបោរ កុប្បកម្ម ការជុះផ្ទុះ ព្រមទាំងព្រឹត្តិការណ៍ ឬ ការៈ ទេសៈផ្សេងៗទៀត ដែលហួសពីការគ្រប់គ្រងសមស្របរបស់ភាគីទាំងពីរ ។

## ប្រការ ១៩ : សិទ្ធិលើធនធានធម្មជាតិ និង កេរដំណែល

១៩.១ ប្រសិនបើមានឈើដែលមានតំលៃពាណិជ្ជកម្មនៅសេសសល់លើដីដែលភាគី "ក" ប្រគល់ជូនទៅភាគី "ខ" ភាគី "ខ" ត្រូវបង់ថ្លៃឈើជូនភាគី "ក" ដោយផ្អែកតាមច្បាប់គ្រប់គ្រងព្រៃឈើជាធរមាន នៃព្រះរាជាណាចក្រ កម្ពុជា ។

១៩.២ នៅក្នុងការកាប់គាស់ដីសំរាប់ធ្វើផលិតកម្ម-អាជីវកម្ម ប្រសិនបើភាគី "ខ" រកឃើញ រ៉ែ ត្បូង មាស ឬ វត្ថុដែលជាកេរដំណែលផ្សេងៗ របស់ជាតិ នៅលើដី ឬក្រោមដី ត្រូវទុកជាទ្រព្យសម្បត្តិរដ្ឋ ។

## ប្រការ ២០ : ភាសា

កិច្ចសន្យានេះធ្វើឡើងនៅរាជធានីភ្នំពេញ ជាពីរភាសា គឺភាសាខ្មែរ និង ភាសាអង់គ្លេសចំនួន ១៥ច្បាប់ ច្បាប់និមួយៗ មានតំលៃស្មើៗគ្នា ។ ក្នុងការខ្វែងគំនិតគ្នា ត្រូវយកភាសាខ្មែរ និងអង់គ្លេសជាមូលដ្ឋាន ។

## ប្រការ ២១ : ការចាប់ផ្តើម និង បញ្ចប់កិច្ចសន្យា

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី20...ខែ..04..ឆ្នាំ ២០០១ ហើយត្រូវផុតកំណត់នៅ ថ្ងៃទី20. ខែ...04.....ឆ្នាំ ២០៧១ ។

ដើម្បីជាសក្ខីភាព ភាគី "ក" និងភាគី "ខ" បានឯកភាពលើអាណត្តិ និង លក្ខខ័ណ្ឌដែលបានចែងក្នុងកិច្ចសន្យានេះ តាមការបរិច្ឆេទខាងដើម ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី.20.ខែ..04....ឆ្នាំ ២០០១

| តំណាងភាគី "ខ" | តំណាងភាគី "ក" |
| --- | --- |
| នាយកក្រុមហ៊ុន ស៊ីជេ ខាំបូឌា ចំកាត់ | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | រដ្ឋមន្ត្រីស្តីទី |

__កន្លែងតំកល់ឯកសារ :__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងរៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី
- ក្រសួងឧស្សាហ៍កម្ម រ៉ែ និង ថាមពល
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពង់ស្ពឺ
- មន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ
- ភាគី "ក"
- ភាគី "ខ"
- កាលប្បវត្តិ-ឯកសារ